**The Royal Women's Hospital Women's Health Information**

# ការព្យាបាល endometriosis (ជំងឺស្រទាប់ក្នុងរបស់ស្បូននៅខុសកន្លែង)

*មីនា ឆ្នាំ 2004*

## តើមានអ្វីកើតឡើងទៅ បើមិនព្យាបាល endometriosis ទេនោះ?

ជំងឺ endometriosis មិនសូវធ្ងន់ធ្ងរ មិនចាំបាច់តែងតែទទួលការព្យាបាលឡើយ។ ជាធម្មតា គេស្នើផ្តល់ការព្យាបាលឲ្យអ្នក ដើម្បីជួយសំរាលរោគសញ្ញា ជាជាង"ព្យាបាលសះស្បើយ"ជំងឺនេះតែម្តង។

បើមិនព្យាបាលទេ endometriosis ខ្លះនឹងបានគ្រាន់បើដោយគ្មានជំនួយឡើយ ប៉ុន្តែភាគច្រើននឹងនៅឯដដែល។ រោគនេះខ្លះ នឹងរឹតតែមានភាពធ្ងន់ធ្ងរឡើង បើមិនព្យាបាលទេនោះ។

ចំពោះស្ត្រីភាគច្រើនដែលមាន endometriosis រោគសញ្ញានឹងធូរស្រាលនៅពេលដែលស្ត្រីទាំងនោះឆ្លងកាត់រួចនូវភាពលែង មានរដូវតទៅទៀត។ ការសំរេចថាតើព្យាបាល endometriosis ឬទេនោះ ជាញឹកញយគឺជាបញ្ហានៃការថ្លឹងថ្លែងនូវលទ្ធភាព គ្រោះថ្នាក់នៃការព្យាបាល ដោយប្រៀបធៀបនឹងផលប៉ះពាល់ដែល endometriosis កំពុងមានលើជីវិតរបស់អ្នក។

## តើមានការព្យាបាលអ្វីខ្លះទៅ?

ជំងឺ endometriosis អាចព្យាបាលតាមវិធីវេជ្ជសាស្ត្រ (ដោយប្រើថ្នាំពេទ្យ) ឬ តាមការវះកាត់។ ជួនកាលទៅ គេប្រើទាំងថ្នាំ ពេទ្យ និង ទាំងការវះកាត់។ ស្ត្រីខ្លះក៏ទទួលប្រយោជន៍ពីការព្យាបាលតាមវិធីផ្សេងដែរ។ ថ្នាំពេទ្យមានចាប់ពីថ្នាំសំរាលការឈឺចាប់ (ដូចជាប៉ារ៉ាសេតាម៉ុល និង ថ្នាំប្រឆាំងភាពរលាកដែលគ្មានស្តេរ៉ូអ៊ីដ) រហូតដល់ការព្យាបាលប្រើអ័រម៉ូន ដែលទប់សកម្មភាព នៃការបញ្ចេញពងមេជីវិតស្ត្រីពីអូវែរ និង ការមានរដូវ។

ការវះកាត់អាចប្រើសំរាប់កាត់យកចេញ ឬ ដុត endometriosis ។ ការវះកាត់ទូទៅបំផុតដែលប្រើ គឺ វិធីវះឆ្លុះមើលក្នុងសំបុក ពោះ (laparoscopy) (ចោះប្រហោងតូច)។

បើអូវែរមានពងដុះនៃ endometriosis នោះការវះកាត់គឺជាការព្យាបាលល្អបំផុត ដោយសារតែពងដុះនេះមិនទំនងជាបាត់រូបរាង ដោយខ្លួនវាទេ ហើយមិនអាចព្យាបាលដោយថ្នាំពេទ្យឡើយ។

## ការព្យាបាលសំរាប់ភាពមិនអាចមានកូន

ការវះកាត់ត្រូវបានបង្ហាញថា បានកែលំអភាពអាចមានកូនចំពោះស្ត្រីដែលមាន endometriosis មិនសូវធ្ងន់ធ្ងរ។ ការព្យាបាល endometriosis ធ្ងន់ធ្ងរជាងនេះ ជាពិសេសបើមានពងដុះនៅក្នុងអូវែរ ក៏ទំនងជាកែលំអដល់ភាពអាចមានកូនដែរ ទោះជា ពុំមានភស្តុតាងពេញលេញក៏ដោយ។

គេមិនបានបង្ហាញថា ថ្នាំពេទ្យកែលំអភាពអាចមានកូនឡើយ។

គេគួរពិនិត្យមើលមូលហេតុឯទៀតនៃភាពមិនអាចមានកូន ហើយព្យាបាលវា។

# ការព្យាបាលការឈឺចាប់

នៅពេលដែលការឈឺចាប់គឺជាបញ្ហាចំបងក្តី ក៏ការព្យាបាលមានគោលបំណងសំរាលរោគសញ្ញា និង បន្ធូរការឈឺចាប់ដែរ។ ការព្យាបាលចំបងគឺ :

- ថ្នាំសំរាលការឈឺចាប់សាមញ្ញ (ប៉ារ៉ាសេតាម៉ុល ជាដើម)
- ការព្យាបាលប្រើអ័រម៉ូន (ថ្នាំគ្រាប់ ជាដើម)
- ការវះកាត់។

*ថ្នាំសំរាលការឈឺចាប់សាមញ្ញ*

ស្ត្រីជាច្រើននឹងជួបប្រទះនឹងរោគសញ្ញាធូរស្រាលខ្លះ ដោយប្រើថ្នាំទិញដោយមិនបាច់មានវេជ្ជបញ្ជា ដូចជាប៉ារ៉ាសេតាម៉ុល (Panadol®) និងថ្នាំប្រឆាំងការរលាកគ្មានស្តេរ៉ូអ៊ីដ (Ponstan®, Nurofen®, Naprogesic® ជាដើម)។

*ការព្យាបាលប្រើអ័រម៉ូន*

ការព្យាបាលប្រើអ័រម៉ូន ត្រូវបានប្រើដើម្បីទប់សកម្មភាពនៃដំណើរមានរដូវធម្មតា ហើយជាលទ្ធផល នឹងបញ្ឈប់ ឬ ពន្យឺតការលូត លាស់នៃ endometriosis ។ វិធីសាមញ្ញបំផុតដើម្បីសំរេចការព្យាបាលនេះ គឺការប្រើ "the pill" (ថ្នាំគ្រាប់)។ ក៏មានការព្យា បាលប្រើអ័រម៉ូនផ្សេងទៀត ដែលបានបង្ហាញថាមានប្រសិទ្ធភាពក្នុងការកាត់បន្ថយការឈឺចាប់ទាក់ទងនឹង endometriosis ដែរ។

ស្ត្រីខ្លះនឹងជួបប្រទះនឹងផលវិបាកដោយសារតែការព្យាបាលប្រើអ័រម៉ូន។

*ការវះកាត់*

គេអាចស្នើផ្តល់ការវះកាត់នៅគ្រាដំបូង ដើម្បីជួយធ្វើរោគវិនិច្ឆ័យ។ ស្ត្រីខ្លះត្រូវបានស្នើផ្តល់នូវការវះកាត់ ដោយសារតែស្ត្រីទាំង នោះមិនចង់ប្រើថ្នាំពេទ្យ ឬ ដោយសារតែថ្នាំពេទ្យពុំមានប្រសិទ្ធភាពឡើយ។

គោលបំណងនៃ **វិធីវះឆ្លុះមើលក្នុងសំបុកពោះ (laparoscopy)** (វះប្រហោងតូច) គឺដើម្បីធ្វើរោគវិនិច្ឆ័យ ហើយព្យាបាល endometriosis ដែលមើលឃើញទាំងអស់។ វិធីនេះត្រូវបានធ្វើឡើងដោយប្រើឡាស៊ែរ ឬ កម្តៅអគ្គិសនី ដែលបំផ្លាញ endometriosis តាមរយៈការដុតវា។ ជំរើសផ្សេងពីនេះគឺថា គេអាចកាត់យកដុំ endometriosis ចេញ។

**(សូមអានផងដែរនូវ : ប័ណ្ណពត៌មាន *ការព្យាបាល endometriosis (ជំងឺស្រទាប់ក្នុងរបស់ស្បូននៅខុសកន្លែង) ដោយប្រើវិធីវះឆ្លុះមើលក្នុងសំបុកពោះ)***

ស្ត្រីមួយក្រុមតូចដែលមានរោគសញ្ញាធ្ងន់ធ្ងរ ហើយដែលគ្មានការធូរស្រាលដោយសារថ្នាំពេទ្យឬការព្យាបាលវះកាត់ឯទៀត គេអាចពិចារណាលើការវះកាត់ធំដុំ ដូចជាកាត់ស្បូនចេញ និង កាត់អូវ៉ែរចេញ។

ជួនកាលទៅ endometriosis មានផលប៉ះពាល់ដល់ស្រទាប់ជញ្ជាំងនៃពោះវៀន។ នៅពេលដែលហេតុការណ៍នេះកំពុងបណ្តាលឲ្យមានរោគសញ្ញាខ្លាំងនោះ គេអាចស្នើឲ្យកាត់យកចេញនូវកំណាត់ពោះវៀនដែលរងផលប៉ះពាល់នោះ។ ការវះកាត់នេះ នឹងជាប់ទាក់ទងនឹងការវះកាត់ពោះវៀន ហើយជាការវះកាត់មិនធម្មតាឡើយ។

## ជំរើសនៃការព្យាបាល
### កិច្ចការត្រូវពិចារណា

**មិនធ្វើអ្វីទេ (មិនព្យាបាល) :**

*គុណសម្បត្តិ*

- គ្មានផលវិបាកដោយសារថ្នាំពេទ្យ
- គ្មានលទ្ធភាពគ្រោះថ្នាក់ដោយសារការវះកាត់
- រោគសញ្ញាអាចមានភាពប្រសើរឡើងដោយខ្លួនឯង។

*គុណវិបត្តិ*

- រោគសញ្ញាភាគច្រើន មានតទៅទៀត
- រោគសញ្ញាខ្លះ អាចធ្ងន់ធ្ងរឡើង។

**ថ្នាំសំរាលការឈឺចាប់យ៉ាងសាមញ្ញ (Paracetamol, Nurofen®):**

*គុណសម្បត្តិ*

- ងាយទិញ
- ផលវិបាកមិនកើតមានជាទូទៅទេ

*គុណវិបត្តិ*

- ជាញឹកញយ គឺគ្មានប្រសិទ្ធភាពទេ
- លទ្ធភាពដំបៅក្រពះ ដោយសារថ្នាំ Nurofen® ជាដើម។

**ថ្នាំពេទ្យដូច Progesterone:**

*គុណសម្បត្តិ*

- ការឈឺចាប់ចុះអន់ថយ
- រដូវមិនប្រក្រតី ឬ គ្មានរដូវ
- បញ្ឈប់ការលូតលាស់របស់ endometriosis នៅក្នុងករណីភាគច្រើន
- ថ្នាំខ្លះគឺជាថ្នាំបង្ការកុំឲ្យមានផ្ទៃពោះ។

*គុណវិបត្តិ*

- ផលវិបាក - ឡើងទម្ងន់ ឆាប់ប្តូរអារម្មណ៍ កើតមុន សក់កាន់តែច្រើន ឈឺរមួលសាច់ដុំ ស្រៀវដោះ
- រោគសញ្ញាអាចកើតមានសាជាថ្មី នៅពេលឈប់ព្យាបាល
- ប្រហែលជាមិនអាចព្យាបាលការឈឺចាប់
- គ្មានកែលំអភាពអាចមានកូន
- មិនគួរមានផ្ទៃពោះ នៅពេលកំពុងប្រើថ្នាំ
- មិនបង្ការកុំឲ្យមានផ្ទៃពោះទាំងអស់ឡើយ។

**ថ្នាំពេទ្យបណ្តាលឲ្យលែងមានរដូវតទៅទៀត :**

*គុណសម្បត្តិ*

- គ្មានរដូវ
- ការឈឺចាប់ចុះថយ
- បញ្ឈប់ការលូតលាស់របស់ endometriosis នៅក្នុងករណីភាគច្រើន។

*គុណវិបត្តិ*

- ផលវិបាក - ក្តៅកញ្ជ្រោល បែកញើស
- ឆ្អឹងស្តើង បើប្រើច្រើនជាងប្រាំមួយខែ
- រោគសញ្ញាអាចកើតមានសាជាថ្មី នៅពេលឈប់ព្យាបាល
- មិនគួរមានផ្ទៃពោះ នៅពេលកំពុងប្រើថ្នាំ
- មិនមែនបង្ការកុំឲ្យមានផ្ទៃពោះឡើយ
- ប្រហែលជាមិនអាចព្យាបាលការឈឺចាប់។

**ថ្នាំគួបផ្សំបង្ការកុំឲ្យមានផ្ទៃពោះ :**

*គុណសម្បត្តិ*

- បង្ការមិនឲ្យមានផ្ទៃពោះ
- បន្ថយការឈឺចាប់
- អាចលេបដើម្បីកាត់បន្ថយ ឬ បញ្ឈប់ការឈឺចាប់។

*គុណវិបត្តិ*

- ផលវិបាក - ចង្អោរ ឡើងទម្ងន់
- មិនគួរមានផ្ទៃពោះឡើយ ក្នុងពេលប្រើវា
- លទ្ធភាពគ្រោះថ្នាក់នៃដុំឈាមកកនៅក្នុងជើង ឬ សួត

**Mirena IUD:**

នេះនៅតែជាការព្យាបាលពិសោធន៍សំរាប់ endometriosis ប៉ុន្តែអាចមានប្រយោជន៍ បើត្រូវការវិធីបង្ការកុំឲ្យមានផ្ទៃពោះ ហើយរោគសញ្ញាតម្រូវឲ្យប្រើវា។

**វិធីវះឆ្លុះមើលក្នុងសំបុកពោះ (laparoscopy)**

*គុណសម្បត្តិ*

- រោគវិនិច្ឆ័យពិតប្រាកដ
- ការព្យាបាលសះស្បើយរយៈពេលយូរចំពោះស្ត្រីដល់ទៅ 70%
- មិនត្រូវការប្រើថ្នាំពេទ្យ នៅរយៈពេលយូរឡើយ។

*គុណវិបត្តិ*

- មិនអាចព្យាបាល endometriosis ទាំងអស់ តាមវិធីនេះឡើយ
- មានលទ្ធភាពគ្រោះថ្នាក់ដោយសារការវះកាត់
- ប្រហែលជាមិនអាចព្យាបាលការឈឺចាប់ឲ្យបានសះស្បើយឡើយ
- endometriosis កើតមានសាជាថ្មី ចំពោះស្ត្រី 30%។

**ការកាត់ស្បូនចេញ និង ការយក endometriosis ចេញ :**

*គុណសម្បត្តិ*

- សំរេចការព្យាបាលសះស្បើយរយៈពេលយូរ ចំពោះស្ត្រីជាង 90%
- មិនត្រូវការប្រើថ្នាំពេទ្យទេ
- គ្មានរដូវតទៅទៀតឡើយ។

*គុណវិបត្តិ*

- លទ្ធភាពគ្រោះថ្នាក់ដោយសារការវះកាត់ មានទំហំធំជាងវិធីវះឆ្លុះមើលក្នុងសំបុកពោះ
- ដកយកចេញនូវភាពអាចមានផ្ទៃពោះ
- ស្ត្រីខ្លះមានសេចក្តីទុក្ខសោកដោយសារតែការបាត់បង់ស្បូន
- អាចត្រូវការ HRT បើត្រូវកាត់យកអូវែរចេញ
- ប្រហែលជាមិនអាចព្យាបាលការឈឺចាប់ឲ្យសះស្បើយឡើយ។

## វិធីព្យាបាលផ្សេងទៀតនិងបង្គ្រប់បន្ថែម

មានវិធីព្យាបាលផ្សេងៗដែលអាចបង្គ្រប់បន្ថែមលើការព្យាបាលវេជ្ជសាស្ត្ររបស់លោកអ្នក ឬ ក៏ជាជំរើសផ្សេងទៅនឹងការព្យាបាលវេជ្ជសាស្ត្រដែរ។ ការព្យាបាលមានប្រជាប្រិយបំផុតគឺថ្នាំចិនសែ និង ថ្នាំគ្រឿងរុក្ខជាតិ។ ស្ត្រីខ្លះមានរោគសញ្ញារបស់ខ្លួនកែលំអឡើងតាមរយៈវិធីទាំងនេះ ប៉ុន្តែពុំមានភស្តុតាងវិទ្យាសាស្ត្រនៅឡើយដែលថា ថ្នាំចិនសែ អាចកាត់បន្ថយរោគសញ្ញា ឬ កែលំអភាពអាចមានផ្ទៃពោះ។

បើអ្នកប្រើវិធីព្យាបាលបង្គ្រប់បន្ថែម វាជាការមួយប្រសើរក្នុងការពិភាក្សានូវការប្រើវិធីទាំងនេះជាមួយវេជ្ជបណ្ឌិតអ្នកដោយ សារតែវិធីនេះអាចជ្រៀតជ្រែកដល់ការប្រើថ្នាំផ្សេងទៀតដែលប្រាប់ឲ្យប្រើដោយវេជ្ជបណ្ឌិត។ Pharmaceutical Benefits Scheme (PBS) (គំរោងជំនួយថ្លៃឱសថ) មិនជួយបង់ថ្លៃវិធីព្យាបាលផ្សេងទៀតឬវិធីព្យាបាលបង្គ្រប់បន្ថែមឡើយ។

## ពេលដែលការព្យាបាលមិនកែលំអរោគសញ្ញា

ការព្យាបាលចុងក្រោយនៃ endometriosis គឺការកាត់ស្បូនចេញ - ដែលត្រូវតែកាត់យកស្បូន និង កាត់យកអូវែរចេញហើយនិង endometriosis ទាំងអស់។ នេះជាការវះកាត់ធំ ហើយមានន័យថាពុំមានលទ្ធភាពមានផ្ទៃពោះតទៅទៀតឡើយ។ ជាអកុសល ស្ត្រីខ្លះនឹងនៅតែមានរោគសញ្ញាដដែលទោះជាវាជាការច្បាស់ណាស់ដែលថា endometriosis ទាំងអស់ បានទទួលការព្យាបាលមានប្រសិទ្ធភាពក៏ដោយ។

វាក៏មានលទ្ធភាពផងដែរថា នៅពេលដែលថ្នាំពេទ្យឬការវះកាត់មិនកែលំអរោគសញ្ញាទេ នោះរោគសញ្ញានេះប្រហែលជាមិនមែនដោយសារតែ endometriosis ឡើយ។ នៅក្នុងស្ថានការណ៍នេះ អ្នកអាចត្រូវការស៊ើបអង្កេតបន្ថែម ដើម្បីពិនិត្យរកមើលលទ្ធភាពនៃមូលហេតុផ្សេងទៀត ចំពោះរោគសញ្ញារបស់អ្នក។ ស្ត្រីខ្លះនឹងមិនរកឃើញមូលហេតុនៃការឈឺចាប់ របស់ខ្លួនទាល់តែសោះហើយនឹងទទួលការព្យាបាលដើម្បីកាត់បន្ថយរោគសញ្ញា និងកែលំអគុណភាពជីវិតរបស់ខ្លួនតែប៉ុណ្ណោះ។

## បើមិនមែនជា endometriosis ទេ តើវាជាអ្វីទៅ?

ការឈឺចាប់នៅម្តុំសាច់ដុំឆ្អឹងត្រគាក អាចបណ្តាលដោយស្ថានភាពជំងឺស្ត្រីមួយចំនួន ដោយមានរួមទាំង :

- adenomyosis (ស្ថានភាពមួយដែលស្រទាប់ក្នុងរបស់ស្បូន ជ្រៀតចូលក្នុងសាច់ដុំស្បូន)
- ដំបៅម្តុំសាច់ដុំឆ្អឹងត្រគាក ដូចជា Chlamydia
- ជាលិកាមានស្លាកស្នាម (ស្អិតជាប់) ដែលបណ្តាលដោយការវះកាត់លើកមុន
- ដំបៅ ឬ ជំងឺរលាកម្តុំសាច់ដុំឆ្អឹងត្រគាក ដែលចាស់យូរមកហើយ
- ពងដុះ នៅលើអូវែរ។

ការឈឺចាប់នៅម្តុំសាច់ដុំឆ្អឹងត្រគាក ក៏អាចបណ្តាលដោយស្ថានភាពឯទៀតដែលមិនមែនជារោគស្ត្រីផងដែរ ដូចជា:

- រោគសញ្ញាពោះវៀនដែលធ្វើឲ្យរសាប់រសល់
- ជំងឺរលាកពោះវៀន (ឧទាហរណ៍: ជំងឺ Crohn)
- បញ្ហាប្លោកនោម ដូចជាជំបៅ ឬ រលាករ៉ាំរ៉ៃ។

ស្ត្រីដែលមានការឈឺចាប់នៅម្តុំសាច់ដុំឆ្អឹងត្រគាក ប្រហែលជាពុំមានមូលហេតុរាងកាយដែលអាចឲ្យស្គាល់នឹងទេ ប៉ុន្តែ ជួនកាលទៅ វាអាច ឬ មានភាពរឹតតែធ្ងន់ធ្ងរ ដោយសារតែកត្តាផ្លូវចិត្ត ដោយមានរួមទាំងអំពើមិនត្រឹមត្រូវនៃការរួមរ័ក ឬ អំពើមិនត្រឹមត្រូវទៅលើរាងកាយ កាលពីគ្រាមុន។

ទីបញ្ចប់ ការឈឺចាប់នេះអាចកើតមានចំពោះស្ត្រីដែលទំនងជាមានសុខភាពបង្កើតកូននិងអ័រម៉ូនធម្មតា។ វេជ្ជបណ្ឌិត ប្រហែលជាមិនដឹងមូលហេតដែលកំពុងបណ្តាលឲ្យមានការឈឺចាប់ឡើយ។

## ទីកន្លែងទទួលពត៌មានបន្ថែម

**Women's Health Information Centre (RWH)**
(03) 8345 3045
1800 442 007 (ទូរស័ព្ទឥតគិតថ្លៃ) អ៊ីមែល : whic@thewomens.org.au

http://www.thewomens.org.au

**Endometriosis Association of Victoria**
567 Waterdale Road
Heidelberg West
Victoria 3081
Australia
(03) 9457 2933
http://www.endometriosis.org.au/

**Gynaecology Clinic** (គ្លីនិកជំងឺស្ត្រី) នៅ **Royal Women's Hospital**

គ្លីនិកនេះ មានទីតាំងនៅក្នុងអគារ outpatients (អ្នកជំងឺនៅក្រៅមន្ទីរពេទ្យ) នៅនឹងជាន់ក្រោមនៃ Royal Women's Hospital
ទូរស័ព្ទ (03) 8344 2000

## ប័ណ្ណពត៌មានឯទៀតរបស់ RWH ដែលអាចមានប្រយោជន៍សំរាប់អ្នក

RWH មានប័ណ្ណពត៌មានផ្សេងៗជាភាសាច្រើន នៅតាមអ៊ីនធើរណិត។ បើអ្នកចង់បានពត៌មានបន្ថែម អ្នកអាចបើក មើលវិបសៃផ្សព្វផ្សាយសុខភាពរបស់យើង។ អាសយដ្ឋានគឺ http://www.thewomens.org.au

អ្នកក៏អាចសុំឲ្យអ្នកថែទាំអ្នកនៅ Royal Women's Hospital ផ្តល់ប័ណ្ណពត៌មានផងដែរ។ សុំយក :

- *Endometriosis (ជំងឺស្រទាប់ក្នុងរបស់ស្បូននៅខុសកន្លែង) - ពត៌មានសំរាប់ស្ត្រី*
- *ការព្យាបាល endometriosis*

*(ជំងឺស្រទាប់ក្នុងរបស់ស្បូននៅខុសកន្លែង)ដោយប្រើវិធីវះឆ្លុះមើលក្នុងសំបុកពោះ*

- *ហេតុការណ៍គោលការណ៍អំពីវិធីបង្ការកុំឲ្យមានផ្ទៃពោះ - IUD*